ក្រសួងការពារជាតិ


ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សារជូនពរ

## សូមគោរពជូន

## សម្ដេចតេជោ ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ

**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

ក្នុងឱកាសដ៏មង្គលសួស្ដីប្រសើរថ្លៃថ្លា ប្រកបដោយសេចក្ដីសោមនស្សរីករាយ នៃការទទួលអំណរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំនិងភរិយា សូមជូននូវសព្ទសាធុការពរជ័យ សិរីមង្គល មហាប្រសើរជូន **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ ដើម្បីបំពេញសកម្មភាពមនុស្សធម៌និងដឹកនាំកាកបាទក្រហមកម្ពុជា ឱ្យទទួលបានជោគជ័យថ្មីៗថែមទៀត។

យើងខ្ញុំទាំងអស់គ្នា សូមកោតសរសើរចំពោះវីរភាពដឹកនាំដ៏ឈ្លាសវៃ របស់ **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** ក្នុងកិច្ចខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី បំពេញភារកិច្ចដ៏ឧត្ដុង្គឧត្ដមក្នុងបុព្វហេតុបម្រើជាតិមាតុភូមិនិងប្រជាជនប្រកបដោយឆន្ទៈមោះមុតខ្លាំងក្លា។ **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** ជាអ្នកដឹកនាំស្ត្រីដ៏ឆ្នើមមួយរូប ហើយក៏បានដើរតួនាទីយ៉ាងសំខាន់ រួមចំណែកជាមួយរាជរដ្ឋាភិបាល លើកកម្ពស់សេចក្ដីថ្លៃថ្នូរ កិត្តិយស តួនាទីរបស់ស្ត្រីនៅក្នុងសង្គមកាន់តែទូលំទូលាយ ក្នុងនោះសកម្មភាពមនុស្សធម៌ជួយចែករំលែក និងដោះស្រាយរាល់ទុក្ខលំបាករបស់ប្រជាពលរដ្ឋដែលទទួលរងគ្រោះមហន្តរាយផ្សេងៗបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាពខ្ពស់ ទទួលបានការគាំទ្រយ៉ាងភ្លៀវភ្លាពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ។

ជាថ្មីម្ដងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ក្នុងនាមខ្ញុំនិងភរិយា សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតាឆ្នាំថ្មី ទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមតាមជួយថែរក្សាការពារប្រោះព្រំ ជូន **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** ឧត្ដមភរិយា **សម្ដេចតេជោ នាយករដ្ឋមន្ត្រី** ព្រមទាំងបុត្រាបុត្រី និងចៅប្រុសចៅស្រីជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃអង្គារ ១កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្ដេចពិជ័យសេនា **ទៀ បាញ់**


វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ០២៣ ៨៨៣ ២៧៥: generalsec@mod.gov.kh